ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 01 / 2016
ម៉ោង (Time/Heure): 13:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SAMAN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

**សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥

## សវនាការលើភស្តុតាង - ថ្ងៃ ៣៤០

រៀបចំដោយ៖ **ជា ស៊ីវហ៊ង** និង **Roger PHILLIPS**

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ , ចៅក្រម Jean-Marc LAVERGNE , ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, Martin KAROPKIN |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ង, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicolas KOUMJIAN , លោក Dale LYSAK, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSÉ |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក ពេជ អង្គ, លោក ហុង គឹមសួន, លោក វ៉ែន ពៅ |
| សាក្សី/ដើមបណ្ដឹង៖ 2-TCW-918 |
| មេធាវីប្រឹក្សា៖ លោក ម៉ម រិទ្ធា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, លោក ឡូញ ង៉ែត, កញ្ញា ស្រី ណាក់, កញ្ញា សុក សុភ័គមណីកា, កញ្ញា Clémentine PLAGNOL |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥ | ចាប់ផ្ដើមម៉ោង៖ ០៩.០៦ | បញ្ចប់ម៉ោង៖ ១៦.០៦ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ០៩.១៩ | បញ្ចប់ម៉ោង៖ ១០.០០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១១.៣២០៣ | បញ្ចប់ម៉ោង៖ ១៣.៣២ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ ១៤.៤៦ | បញ្ចប់ម៉ោង៖ ១៥.០៩ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៣ ម៉ោង និង ៥៧ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៧ | ០៩.០៧ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្ដី នួន ជា | ០៩.០៨ | ០៩.០៩ |
| សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន និង សហព្រះរាជអាជ្ញា សុំឱ្យលុបចោលសេចក្ដីបង្គាប់នៅក្នុងឯកសារ E319/7/3 (E376 និង E376/1) | អង្គជំនុំជម្រះ | ០៩.១០<br>១០.០០<br>១០.១៦ | ០៩.១១<br>១០.០៨<br>១០.២១ |
| | សហព្រះរាជអាជ្ញា | ០៩.១២<br>១០.០៨<br>១០.១៣ | ០៩.១៥<br>១០.១០<br>១០.១៥ |
| | សហមេធាវីនាំមុខ | ០៩.១៥ | ០៩.១៥ |

| | | | |
|---|---|---|---|
| | មេធាវីការពារក្ដី នួន ជា<br>មេធាវីកាពារក្ដី ខៀវ សំផន | ០៩.១៦<br>០៩.១៧<br>១០.១០ | ០៩.១៦<br>០៩.១៨<br>១០.១៣ |
| ការតាំងសំណួរទៅកាន់សាក្សី<br>2-TCW-918 | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១០.២១<br>១០.២៧ | ១០.២៧<br>១៦.០៦ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ដោយឡែកជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន និង សហព្រះរាជអាជ្ញាសុំឱ្យលុបចោលសេចក្តីបង្គាប់នៅក្នុងឯកសារ E319/7/3 (E376 និង E376/1)**

អង្គជំនុំជម្រះបានចង្អុលបង្ហាញថាខ្លួនបានទទួលនូវឯកសារ E319/35 និង E319/35/2 ពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិដោយបានលើកឡើងនូវបញ្ហាថ្មី។ បន្ទាប់ពីទទួលបានសំណើបន្ថែមទៀត សហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី ខៀវ សំផន រក្សានូវជំហររបស់ខ្លួនដដែល។ សហមេធាវីនាំមុខ និងក្រុមមេធាវីការពារក្តី នួន ជា មិនមានយោបល់អ្វីបន្ថែមនោះទេ។ អង្គជំនុំជម្រះបានសម្រេចលុបចោលនូវសេចក្តីបង្គាប់របស់ខ្លួនក្នុងឯកសារ E319/7/3។ សេចក្តីសម្រេចពីមុនដែលមាននៅក្នុងឯកសារ E319/7 នៅតែចូលជាធរមាន និងមានសុពលភាពដោយត្រូវអនុលោមតាមសេចក្តីណែនាំបន្ថែមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ អង្គជំនុំជម្រះតម្រូវឱ្យប្រើប្រាស់របស្សនាមចំពោះសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង ០០៣ និង ០០៤ ដែលផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២។

អនុលោមតាមវិធាន២៩នៃវិធានផ្ទៃក្នុង និងមាត្រា៤(១) នៃសេចក្តីណែនាំអនុវត្តស្តីពីវិធាការការពារ អង្គជំនុំជម្រះនឹងអនុវត្តរាល់វិធានការការពារទាំងអស់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបង្គាប់ឱ្យមានសម្រាប់សាក្សីនៃសំណុំរឿង ០០៣ និង ០០៤។ អង្គជំនុំជំនុំជម្រះនឹងជូនដំណឹងទៅសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងភាគីទាំងអស់នៅក្នុងសំណុំរឿង ០០២/០២ អំពីបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនានាដែលត្រូវបានជ្រើសរើសឱ្យមកផ្តល់សក្ខីកម្មទៅលើប្រធានបទនីមួយៗ។ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ខៀវ សំផន បានស្នើសុំឱ្យមានការបញ្ជាក់បន្ថែមថាតើការប្រើប្រាស់រហស្សនាមនេះគឺតម្រូវសម្រាប់បុគ្គលទាំងអស់ដែលបានផ្តល់ចម្លើយនៅក្នុងសំណុំរឿង ០០៣ ឬ ០០៤ ដែរឬយ៉ាងណា ដោយបានស្នើថាការធ្វើដូច្នេះគឺមិនចាំបាច់នោះទេសម្រាប់បុគ្គលដែលធ្លាប់បានផ្តល់ចម្លើយនៅក្នុងសំណុំរឿង ០០២/០២ ឬ ផ្តល់ចម្លើយដល់ DC-Cam ហើយមិនទាន់បានផ្តល់ចម្លើយដល់សហចៅក្រមស៊ើបអង្កេតនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើការនោះទេ។ សហព្រះរាជអាជ្ញាក៏បានស្នើដែរថា សាក្សីអាចបោះបង់ចោលនូវការប្រើប្រាស់រហស្សនាម។ អង្គជំនុំជម្រះបានបញ្ជាក់ថាបញ្ហានេះនឹងត្រូវសម្រេចតាមករណីនីមួយៗ ដោយត្រូវថ្លឹងថ្លែងរវាងតម្រូវការក្នុងការទទួលបាននូវសវនាការជាសាធារណៈ ជាមួយនឹងភាពសម្ងាត់នៃកិច្ចស៊ើបអង្កេតដែលកំពុងដំណើការ។ សម្រាប់សក្សីបន្ទាប់ អង្គជំនុំជម្រះនឹងប្រើប្រាស់រហស្សនាម។

<u>**ការតាំងសំណួរទៅកាន់សាក្សី 2-TCW-918**</u>

អង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានតាំងសំណួរទៅកាន់សាក្សី 2-TCW-918។

## <u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>

Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/178 | D175/4.3 | 00275587-00275598; 00342708-00342723; 00623304-00623321 | Weekly Report of Region 5 Committee, 21 May 1977 | P | 00275497 | 00342721 | 00623318 00623319 |
| E3/1783 | D376.3 | 00659257-00659262; 00498179-00498181; 00606764-00606767 | New China News Agency, Chen Yung-Kuei's Cambodia Visit Reported, 22 December 1977 | P | 00659260 | 00498181 | 00606766 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/771 | D248/4.6 | 00376312-00376349; 00509660-00509690; 00594030-00594059 | Revolutionary Youth Number 7-8 July-August 1977 | P | 00376343 00376344 | 00509686 | 00594053 00594054 |

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9483 | / | 00895155-00895164; 00937031-00937038; 00967788-00967796 | Written record of witness interview of [REDACTED] | C | 00895155 | 00937031 | 00967788 |
| E3/9504 | / | 00727220-00727223; 00738310-00738313; 00755082-00755085 | Written Record of Interview of witness [REDACTED] | C | 00727220 | 00738310 | 00755082 |
| E3/9567 | / | 01003839-01003851; 01044759-01044775; / | Written Record of Interview of [REDACTED] Dated 22-07-2014 | C | 010038448 010038449 | 01044771 01044772 | / |
| E3/9094 | E305/13.23.384 | 00734030-00734120; 00728641-00728705; 01123606-01123663 | Statement of [REDACTED] (DC-Cam) | C | 00734039 00734040 00734044 00734049 00734050 00734059 00734060 00734061 00734065 00734066 00734070 00734071 00734078 00734079 00734080 00734081 00734082 00734084 | 00728647 00728648 00728651 00728654 00728655 00728662 00728663 00728666 00728667 00728670 00728675 00728676 00728677 00728678 00728679 00728680 | 01123611 01123612 01123615 01123618 01123619 01123625 01123626 01123629 01123632 01123633 01123637 01123638 01123639 01123640 01123641 |

| <u>**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**</u> |
| --- |
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៨)<br>• សម្រេចតាមសំណើរបស់មេធាវីការពារក្តី ខៀវ សំផន និង សហព្រះរាជអាជ្ញា ដែលបានស្នើសុំឱ្យអង្គជំនុំជម្រះលុបចោលនូវសេចក្តីណែនាំរបស់ខ្លួនក្នុងឯកសារ E319/7/3 និងរក្សានូវសេចក្តីបង្គាប់នៅក្នុងឯកសារ E319/7 ដោយត្រូវអនុវត្តតាមសេចក្តីណែនាំបន្ថែម។ (១០.០០)<br>• បង្គាប់អោយអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់អោយនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញអោយបានមុនម៉ោង ៩.០០ ព្រឹក នៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥។ (១៦.០៦) |

| <u>**កាលវេលាសវនាការបន្ត**</u> |
| --- |
| សវនាការនឹងបន្តទៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៥ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីវហ៊ង** **Roger PHILLIPS**